ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ....០៤០........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- បានឃើញប្រកាសលេខ ៧៧៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតកម្ពុជា
- បានឃើញប្រកាសលេខ ០១៩ អ.ស.ហ.ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- យោងតាមការអនុម័តនៃសម័យប្រជុំក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីនីតិវិធី និងគោលការណ៍នៃការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ដើម្បីធានាបាននូវគុណភាពនៃសេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនសវនកម្មដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

- **គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង
- **ក្រុមហ៊ុនសវនកម្ម** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មចេញដោយនិយ័តករគណនេយ្យនិងសវនកម្ម។

## ជំពូកទី២

## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីទទួលស្គាល់

**ប្រការ៤.-**

ក្រុមហ៊ុនសវនកម្មដែលមានបំណងផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ត្រូវចុះបញ្ជីទទួលស្គាល់នៅនិយ័តករធានារ៉ាប់រងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា“**ន.ធ.ក.**” ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. មានសកម្មភាពធុរកិច្ចសវនកម្ម យ៉ាងតិច ៣ (បី) ឆ្នាំ គិតមកដល់ថ្ងៃដាក់លិខិតស្នើសុំ

២. មានសវនករជារូបវន្តបុគ្គល យ៉ាងតិច ២(ពីរ) រូប ដែលជាសមាជិកសកម្មជាសវនករប្រតិស្រុតរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មផ្តល់ដោយនិយ័តករគណនេយ្យនិងសវនកម្ម និងមានបទពិសោធន៍យ៉ាងតិច ២ (ពីរ) ឆ្នាំ ពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង

៣. ត្រូវធ្វើប្រតិបត្តិការស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ប្រការ៥.-**

ក្រុមហ៊ុនសវនកម្ម ត្រូវស្នើសុំចុះបញ្ជីទទួលស្គាល់ពី **ន.ធ.ក.** ដោយភ្ជាប់ឯកសារដូចខាងក្រោម៖

១. លិខិតស្នើសុំចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង

២. លក្ខន្តិកៈក្រុមហ៊ុន ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

៣. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ដែលចេញដោយនិយ័តករគណនេយ្យនិងសវនកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

៤. បញ្ជីឈ្មោះសវនករជារូបវន្តបុគ្គល យ៉ាងតិច ២(ពីរ) រូប ដែលជាសមាជិកសកម្មជាសវនករប្រតិស្រុតរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ដោយភ្ជាប់មកនូវវិញ្ញាបនបត្របញ្ជាក់សមាជិកសកម្ម និងប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារ និងការសិក្សា ដោយភ្ជាប់សញ្ញាបត្រនិងវិញ្ញាបនបត្រជំនាញ

៥. របាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួច ក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ ដោយមានប្រថាប់ត្រាក្រុមហ៊ុន

៦. បញ្ជីឈ្មោះអតិថិជននៅក្នុងវិស័យហិរញ្ញវត្ថុ ដែលក្រុមហ៊ុនសវនកម្មបានផ្តល់សេវាសវនកម្ម ក្នុងរយៈពេល ៣(បី) ឆ្នាំចុងក្រោយ ដោយមានប្រថាប់ត្រាក្រុមហ៊ុន

៧. ឯកសារស្តីពីនីតិវិធីសវនកម្ម ឬយន្តការត្រួតពិនិត្យគុណភាពសវនកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

៨. បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល

៩. ឯកសារពាក់ព័ន្ធផ្សេងទៀតដែលតម្រូវដោយ **ន.ធ.ក.**។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់ការចុះបញ្ជីទទួលស្គាល់ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៦.-**

ការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង មានសុពលភាព ៣(បី) ឆ្នាំ។

**ប្រការ៧.-**

ក្រុមហ៊ុនសវនកម្មដែលមានបំណងបន្តផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ត្រូវស្នើសុំបន្តសុពលភាពនៃការចុះបញ្ជីទទួលស្គាល់ មក**ន.ធ.ក.** ឱ្យបានមុនរយៈពេល ៤៥(សែសិបប្រាំ) ថ្ងៃ នៃកាលបរិច្ឆេទផុតសុពលភាពនៃការចុះបញ្ជីទទួលស្គាល់ ដោយភ្ជាប់ឯកសារដូចខាងក្រោម៖

១. លិខិតស្នើសុំបន្តសុពលភាពនៃការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង

២. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មនៅមានសុពលភាព ដែលចេញដោយនិយ័តករគណនេយ្យនិងសវនកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

៣. បញ្ជីឈ្មោះសវនករជារូបវន្តបុគ្គល យ៉ាងតិច ២(ពីរ) រូប ដែលជាសមាជិកសកម្មជាសវនករប្រតិស្រុតរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ដោយភ្ជាប់មកនូវវិញ្ញាបនបត្របញ្ជាក់សមាជិកសកម្ម និងប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារ និងការសិក្សា ដោយភ្ជាប់សញ្ញាបត្រនិងវិញ្ញាបនបត្រជំនាញ (ប្រសិនបើមានការផ្លាស់ប្តូរ)

៤. ឯកសារស្តីពីនីតិវិធីសវនកម្ម ឬយន្តការត្រួតពិនិត្យគុណភាពសវនកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន (ប្រសិនបើមានការផ្លាស់ប្តូរ)

៥. បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចបន្តសុពលភាពនៃការចុះបញ្ជីទទួលស្គាល់ ឬបដិសេធ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

## ជំពូកទី៣

## លក្ខខណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលបានចុះបញ្ជីទទួលស្គាល់

**ប្រការ៨.-**

គ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រង ត្រូវជ្រើសរើសក្រុមហ៊ុនសវនកម្មដែលបានចុះបញ្ជីទទួលស្គាល់ដោយ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាតពី **ន.ធ.ក.** ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំប្រតិទិននីមួយៗ។

**ប្រការ៩.-**

ក្នុងរយៈពេលនៃការផ្តល់សេវាសវនកម្មជូនគ្រឹះស្ថានធានារ៉ាប់រង ឬបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រងណាមួយ ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង មិនអាចផ្តល់ជូននូវសេវាដូចខាងក្រោម៖

១. សេវាគណនេយ្យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន

២. សេវាបង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យាផ្នែកហិរញ្ញវត្ថុ

៣. សេវាសវនកម្មផ្ទៃក្នុង

៤. សេវាគណនាបុព្វលាភធានារ៉ាប់រង

៥. សេវាផ្តល់ប្រឹក្សាផ្នែកច្បាប់ ផ្នែកវិនិយោគ និងសេវាកម្មពន្ធដារ

៦. សេវាមុខងារគ្រប់គ្រង ឬធនធានមនុស្ស

៧. សេវាពាក់ព័ន្ធនឹងការកំណត់សោធននិវត្តន៍បុគ្គលិក

៨. សេវាផ្សេងទៀតដែល **ន.ធ.ក.** យល់ថាអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

**ប្រការ១០.-**

ក្នុងករណីក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង បានផ្តល់សេវាណាមួយដូចបានរៀបរាប់ក្នុងប្រការ៩ ខាងលើ ដល់គ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រង ក្រុមហ៊ុនមិនអាចផ្តល់សេវាសវនកម្មដល់គ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រងនោះ ក្នុងរយៈពេល៣ (បី) ឆ្នាំ ក្រោយការផ្តល់សេវាខាងលើត្រូវបានបញ្ចប់។

**ប្រការ១១.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង មិនអាចផ្តល់សេវាសវនកម្មដល់គ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រង ដែលខ្លួនទទួលផលប្រយោជន៍ ឬមានសិទ្ធិគ្រប់គ្រង ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី តាមរយៈសហព័ន្ធ ញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬមានទំនាក់ទំនងផ្សេងទៀតដែល **ន.ធ.ក.** យល់ឃើញថាអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

**ប្រការ១២.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង មិនអាចផ្តល់សេវាសវនកម្មដល់គ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រង លើសពីរយៈពេល ៣ (បី) ឆ្នាំបន្តបន្ទាប់ លើកលែងមានការអនុញ្ញាតដោយឡែកពី **ន.ធ.ក.**។

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ដែលត្រូវបានប្តូរចេញពីការធ្វើសវនកម្មលើគ្រឹះស្ថានធានារ៉ាប់រង ឬបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រងណាមួយ អាចត្រឡប់ទៅផ្តល់សេវាសវនកម្មដល់គ្រឹះស្ថានធានារ៉ាប់រងដដែលនោះវិញ បន្ទាប់ពី រយៈពេល ២ (ពីរ) ឆ្នាំ ក្រោយបញ្ចប់ការបំពេញសវនកម្មលើកចុងក្រោយ។

**ប្រការ១៣.-**

ក្នុងករណីចាំបាច់ **ន.ធ.ក.** អាចតម្រូវឱ្យគ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រង ធ្វើការតែងតាំងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ដែលអាចជាក្រុមហ៊ុនកំពុងផ្តល់សេវាសវនកម្ម ឬជាក្រុមហ៊ុនផ្សេងទៀត ឱ្យធ្វើសវនកម្មពិសេសលើផ្នែកណាមួយនៃប្រតិបត្តិការ ឬរបាយការណ៍ណាមួយ តាមការតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ រាល់ចំណាយសម្រាប់ការធ្វើសវនកម្មពិសេសនេះ និងចំណាយពាក់ព័ន្ធផ្សេងទៀត ជាបន្ទុករបស់គ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រងដែលរងសវនកម្ម។

## ជំពូកទី៤

## ភារកិច្ចរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលបានចុះបញ្ជីទទួលស្គាល់

**ប្រការ១៤.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង មានភារកិច្ច ដូចខាងក្រោម៖

១. ត្រូវធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវស្របតាមស្តង់ដាដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា

២. ត្រូវផ្តល់កិច្ចសហការ ការពន្យល់ របាយការណ៍សវនកម្ម និងព័ត៌មានឬទិន្នន័យទាក់ទងនឹងសកម្មភាពសវនកម្ម ករណីមានការតម្រូវដោយ **ន.ធ.ក.** និងត្រូវចែងក្នុងកិច្ចសន្យាធ្វើសវនកម្មជាមួយអតិថិជនអំពីសិទ្ធិរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងការផ្តល់របាយការណ៍ និងព័ត៌មាន ឬទិន្នន័យជូន **ន.ធ.ក.**

៣. ត្រូវរាយការណ៍ជាបន្ទាន់មក **ន.ធ.ក.** ករណីរកឃើញភាពមិនប្រក្រតីណាមួយដូចខាងក្រោម៖
   - ការគេបន្លំ ឬកំហុសរបស់គ្រឹះស្ថានធានារ៉ាប់រងនិងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រង រងសវនកម្ម ដែលអាចបង្កជាហានិភ័យធ្ងន់ធ្ងរដល់គ្រឹះស្ថានធានារ៉ាប់រង និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យធានារ៉ាប់រង ឈានទៅរកអសាធនភាព
   - ការមិនអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
   - សកម្មភាពបច្ចុប្បន្ន ឬផែនការអនាគតដែលអាចបង្កជាផលប៉ះពាល់អវិជ្ជមានដល់ផលប្រយោជន៍របស់អ្នកប្រើប្រាស់សេវាធានារ៉ាប់រង និងភាគីពាក់ព័ន្ធនានា។

៤. ត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃ ក្នុងករណីណាមួយដូចខាងក្រោម៖
   - ការសុំឈប់ ការបញ្ឈប់ ឬការផ្អាកផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ដោយគិតចាប់ពីកាលបរិច្ឆេទសម្រេចដោយក្រុមហ៊ុនផ្តល់សេវាសវនកម្ម

- ការផ្លាស់ប្តូរសវនករជារូបវន្តបុគ្គល តាមលក្ខខណ្ឌតម្រូវ ដោយត្រូវភ្ជាប់មកនូវវិញ្ញាបនបត្របញ្ជាក់សមាជិកសកម្ម និងប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារនិងការសិក្សា ដោយគិតចាប់ពីកាលបរិច្ឆេទសម្រេចរបស់ក្រុមហ៊ុន
- ទទួលទណ្ឌកម្មណាមួយដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចស្តីពីទណ្ឌកម្មនោះ
- ការព្យួរ ឬដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចស្តីពីការព្យួរ ឬដកហូតនោះ
- កែប្រែលក្ខន្តិកៈក្រុមហ៊ុន ដោយត្រូវភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃលក្ខន្តិកៈដែលបានកែប្រែរួចនោះ បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងពាណិជ្ជកម្ម
- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក ដោយគិតចាប់ពីកាលបរិច្ឆេទសម្រេចរបស់ក្រុមហ៊ុន
- មានបញ្ហាស្ថានភាពហិរញ្ញវត្ថុធ្ងន់ធ្ងរដែលអាចឈានទៅរកការក្ស័យធន។

៥. ត្រូវផ្តល់ជូន **ន.ឆ.គ.** នូវៈ

- របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនេះ ត្រូវដាក់ឱ្យរងសវនកម្មឯករាជ្យ ដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលបានចុះបញ្ជីទទួលស្គាល់ដោយ **ន.ឆ.គ.** ឬអាចជ្រើសរើសក្រុមហ៊ុនសវនកម្មផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពី **ន.ឆ.គ.**
- របាយការណ៍លទ្ធផលនៃការត្រួតពិនិត្យគុណភាពសវនកម្មតាមការតម្រូវរបស់ **ន.ឆ.គ.**
- ឯកសារពាក់ព័ន្ធផ្សេងទៀត ដែលតម្រូវដោយ **ន.ឆ.គ.**។

៦. អនុវត្តកាតព្វកិច្ចផ្សេងទៀតដែលតម្រូវដោយ **ន.ឆ.គ.**។

**ប្រការ១៥.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង មានកាតព្វកិច្ចអនុលោមភាព ដូចខាងក្រោមៈ

១. ស្តង់ដាគណនេយ្យដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា

២. ស្តង់ដាសវនកម្មដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា

៣. ក្រមសីលធម៌វិជ្ជាជីវៈ

៤. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ។

## ជំពូកទី៥

## កម្រៃសេវារដ្ឋបាល និងកម្រៃចុះបញ្ជីទទួលស្គាល់

**ប្រការ១៦ ._**

រាល់កម្រៃចុះបញ្ជីទទួលស្គាល់ និងកម្រៃសេវារដ្ឋបាល ត្រូវបង់ចូលគណនីរបស់ **ន.ឆ.គ.**។

**ប្រការ១៧ ._**

ក្រុមហ៊ុនសវនកម្ម ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំចុះបញ្ជីទទួលស្គាល់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល និងសម្រាប់បន្តសុពលភាពនៃការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រងចំនួន ១ ០០០ ០០០(មួយលាន) រៀល។

**ប្រការ១៨ ._**

កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារអនុលោមតាមខ្លឹមសារនៃប្រកាសនេះ មិនត្រូវប្រគល់ឱ្យក្រុមហ៊ុនសវនកម្មវិញឡើយ ទោះបីជាការស្នើសុំត្រូវបដិសេធ។

**ប្រការ១៩ ._**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ត្រូវបង់កម្រៃចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រងជាប្រចាំឆ្នាំ ចំនួន ៤ ០០០ ០០០(បួនលាន) រៀល។ កម្រៃចុះបញ្ជីទទួលស្គាល់សម្រាប់ឆ្នាំដំបូង ត្រូវបង់នៅពេលទទួលបានការសម្រេចផ្តល់ការចុះបញ្ជីទទួលស្គាល់។ កម្រៃចុះបញ្ជីទទួលស្គាល់សម្រាប់ឆ្នាំបន្តបន្ទាប់ ត្រូវបង់ឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃដើមឆ្នាំប្រតិបត្តិការអាជីវកម្ម។

## ជំពូកទី៦

## ការផ្អាក និងការលុបចោលការចុះបញ្ជីទទួលស្គាល់

**ប្រការ២០ ._**

**ន.ឆ.គ.** អាចផ្អាកការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ក្នុងករណីដូចខាងក្រោម៖

១. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម អស់សុពលភាព

២. មានសវនករជារូបវន្តបុគ្គល ដែលជាសមាជិកសកម្មជាសវនករប្រតិស្រុតរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មផ្តល់ដោយនិយ័តករគណនេយ្យនិងសវនកម្ម តិចជាង ២ (ពីរ) រូប ក្នុងរយៈពេល ៣ (បី) ខែ ជាប់គ្នា។

**ប្រការ២១ ._**

**ន.ឆ.គ.** អាចលុបចោលការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រងក្នុងករណីដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម ត្រូវបានដកហូត

២. ប្រព្រឹត្តល្មើសនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាគណនេយ្យនិងសវនកម្ម

៣. ប្រព្រឹត្តល្មើសនឹងក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ២២.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រងដែលត្រូវបានផ្អាក ឬលុបចោលការចុះបញ្ជីទទួលស្គាល់ដូចមានចែងក្នុងប្រការ២០ និងប្រការ២១ នៃប្រកាសនេះ ត្រូវបញ្ឈប់ការផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងពី **ន.ធ.ក.**។

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ដែលត្រូវបានផ្អាកការផ្តល់សេវាសវនកម្ម អាចចាប់ផ្តើមដំណើរការឡើងវិញបាន បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរ ឬលិខិតចុះបញ្ជីទទួលស្គាល់ពី **ន.ធ.ក.**។

## ជំពូកទី៧

## ទណ្ឌកម្មរដ្ឋបាល

**ប្រការ២៣.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រងដែលប្រព្រឹត្តល្មើសនឹងប្រការ៩ ប្រការ១០ ប្រការ១១ ប្រការ១២ ប្រការ១៤ ប្រការ១៥ ប្រការ១៩ និងប្រការ២២ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលពី **ន.ធ.ក.**។

**ន.ធ.ក.** អាចដាក់ទណ្ឌកម្មរដ្ឋបាលណាមួយដូចខាងក្រោម៖

១. ការណែនាំ

២. ការព្រមានជាលាយលក្ខណ៍អក្សរ

៣. ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ

៤. ការព្យួរការចុះបញ្ជីទទួលស្គាល់

៥. ការដកហូតការចុះបញ្ជីទទួលស្គាល់

៦. ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ដែលកំណត់ដោយ **ន.ធ.ក.** ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មុននឹងដាក់ទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងកថាខណ្ឌខាងលើ **ន.ធ.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ២៤.-**

ទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ២៥ _**

អគ្គនាយកនៃ **ន.ធ.ក.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ២៦ _**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៧ _**

អគ្គនាយកនៃ **ន.ធ.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យ គ្រប់ប្រធាននាយកដ្ឋានស្ថិតនៅចំណុះឱ្យ **ន.ធ.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១៥ កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តមអនុប្រធាន និងឯកឧត្តម លោកជំទាវជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២៧
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ